ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៩-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៩៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ចំនួន ៦០ រូប ២០៩៣

១០-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៩៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ នាយទាហានជាន់ខ្ពស់ ចំនួន ១២ រូប ២០៩៥

១០-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៩៨ ស្តីពី ការតែងតាំងឥស្សរជន ចំនួន ០៤ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយមិនទទួលប្រាក់បៀវត្ស ២០៩៦

១០-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៩៩ ស្តីពី ការប្រគល់ភារកិច្ចជូនលោកជំទាវ **គីម ស៊ីផាត់** ឱ្យបំពេញមុខងារជា អគ្គនាយក នៃអគ្គនាយកដ្ឋានសមភាពយេនឌ័រ និងអភិវឌ្ឍន៍សេដ្ឋកិច្ច ក្រសួងកិច្ចការនារី ២០៩៧

១៣-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/២០១ ស្តីពី ការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ឯក ជូន លោកស្រី ឧត្តមសេនីយ៍ទោ **យត់ សុខា** នាយនគរបាលជាតិជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ២០៩៨

១៣-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/២០២ ស្តីពី ការប្រគល់ភារកិច្ចជូន ឯកឧត្តម **សខ់ ស៊ីណាម៉ុខ** ឱ្យបំពេញមុខងារជា អគ្គលេខាធិការរង នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា មានឋានៈស្មើអគ្គនាយក ២០៩៩

១៣-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/២០៣ ស្តីពី ការតម្លើងឋានៈជូនលោកជំទាវ **សុខ ស៊ីថន** ជំនួយការសម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី មានឋានៈស្មើអគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ២១០០

១៣-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/២០៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន និង មន្ត្រីរាជការ ចំនួន ០៨ រូប ២១០១

១៣-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/២០៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ប្រគេនព្រះតេជគុណឃោសបាល **សៅរ៍ មុនី** ២១០២

១៣-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/២០៦ ស្តីពី ការតែងតាំងមន្ត្រីរាជការ ចំនួន ០៤ រូប នៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា ២១០៣

១៣-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/២០៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ នាយទាហានជាន់ខ្ពស់ ចំនួន ០៦ រូប ២១០៥

១៤-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/២០៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ និង នាយនគរបាលខេត្តព្រះសីហនុ ចំនួន ២៥ រូប ២១០៦

១៤-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/២០៩ ស្តីពី ការប្រគល់ភារកិច្ចជូន ឯកឧត្តម **អ៊ុច ម៉ូរ៉ា** ឱ្យបំពេញមុខងារជា ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា មានឋានៈស្មើអគ្គនាយក ជំនួសឯកឧត្តម **ពឹង ស៊ីវឡាយ** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ២១០៨

១៦-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/២១០ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសពនាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២ រូប ២១០៩

១៦-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/២១១ ស្តីពី ការតែងតាំងឥស្សរជន ចំនួន ០៣ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ដោយមិនទទួលប្រាក់បៀវត្ស ២១១០

១៦-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/២១២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ សប្បុរសជន ចំនួន ០២ រូប ២១១១

១៦-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/២១៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ សប្បុរសជន ចំនួន ០៤ រូប ២១១២

១៦-៣-២០១២ - ព្រះរាជក្រឹត្យ នស/រកត/០៣១២/២១៤ ស្តីពី ការប្តូរ និង តម្លើងប្រភេទក្របខ័ណ្ឌ ជូនមន្ត្រីរាជការ ចំនួន ០៩ រូប ពីមន្ត្រីក្នុងឋានន្តរស័ក្តិ នាយក្រមការ ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មន្ត្រីរាជការ ក្នុងឋានន្តរស័ក្តិ អនុមន្ត្រី ជាករណីពិសេស នៅក្រសួងព័ត៌មាន ២១១៣

II.រាជរដ្ឋាភិបាល

អនុក្រឹត្យ

១៦-៣-២០១២ - អនុក្រឹត្យលេខ ៤៤ អនក្រ.បក ស្តីពី ការធ្វើអនុបយោគផ្ទៃដីទំហំ ៧.៦៦៨ ហិកតា ក្នុងតំបន់ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ " គីររម្យ " ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ និង ខេត្តព្រះសីហនុ ២១១៥

១៦-៣-២០១២ -អនុក្រឹត្យលេខ ៤៥ អនក្រ.បក ស្តីពី ការធ្វើអនុបយោគផ្ទៃដីទំហំ ២.០០០ ហិកតា ក្នុងតំបន់ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ " គិរីរម្យ " ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តកំពង់ស្ពឺ ២១១៧

១៦-៣-២០១២ -អនុក្រឹត្យលេខ ៤៦ អនក្រ.បក ស្តីពី ការធ្វើអនុបយោគផ្ទៃដីទំហំ ៦.៨៩២ ហិកតា ក្នុងតំបន់ដែនជំរកសត្វព្រៃភ្នំព្រេច ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តមណ្ឌលគិរី ២១១៩

១៦-៣-២០១២ -អនុក្រឹត្យលេខ ៤៧ អនក្រ.បក ស្តីពី ការធ្វើអនុបយោគផ្ទៃដីទំហំ ៣.១១០ ហិកតា ក្នុងតំបន់ដែនជំរកសត្វព្រៃភ្នំព្រេច ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តមណ្ឌលគិរី ២១២១

១៦-៣-២០១២ -អនុក្រឹត្យលេខ ៤៨ អនក្រ.បក ស្តីពី ការធ្វើអនុបយោគផ្ទៃដីទំហំ ៣.១៣៤ ហិកតា ក្នុងតំបន់ដែនជំរកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តសៀមរាប ២១២៣

២០-៣-២០១២ -អនុក្រឹត្យលេខ ៤៩ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ២១២៥

១៥-៣-២០១២ -អនុក្រឹត្យលេខ ២៩៥ អនក្រ.តត ស្តីពី ការតែងតាំងប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ ២១២៧

១៥-៣-២០១២ -អនុក្រឹត្យលេខ ២៩៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២១២៨

១៥-៣-២០១២ -អនុក្រឹត្យលេខ ២៩៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២១២៩

១៥-៣-២០១២ -អនុក្រឹត្យលេខ ២៩៨ អនក្រ.តត ស្តីពី ការដំឡើងថ្នាក់មន្ត្រីរាជការ ២១៣១

១៥-៣-២០១២ -អនុក្រឹត្យលេខ ២៩៩ អនក្រ.តត ស្តីពី ការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត ២១៣២

១៥-៣-២០១២ -អនុក្រឹត្យលេខ ៣០០ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងនាយនគរបាលជាតិ ២១៣៣

១៦-៣-២០១២ -អនុក្រឹត្យលេខ ៣០១ អនក្រ.តត ស្តីពី ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យព្រះកុសមៈ ២១៣៥

១៦-៣-២០១២ -អនុក្រឹត្យលេខ ៣០២ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ២១៣៧

១៦-៣-២០១២ -អនុក្រឹត្យលេខ ៣០៣ អនក្រ.តត ស្តីពី ការកែសម្រួលឋានន្តរស័ក្តិ និង តែងតាំង មន្ត្រីរាជការ ២១៣៨

១៦-៣-២០១២ -អនុក្រឹត្យលេខ ៣០៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២១៤០

១៦-៣-២០១២ -អនុក្រឹត្យលេខ ៣០៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២១៤២

១៦-៣-២០១២ -អនុក្រឹត្យលេខ ៣០៦ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយនគរបាលជាតិ ២១៤៣

១៩-៣-២០១២ -អនុក្រឹត្យលេខ ៣០៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២១៤៥

១៩-៣-២០១២ -អនុក្រឹត្យលេខ ៣០៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២១៤៦

១៩-៣-២០១២ -អនុក្រឹត្យលេខ ៣០៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២១៤៧

-អនុក្រឹត្យលេខ ៣១០, ៣១១, ៣១២, ៣១៣, ៣១៤, ៣១៥ អនក្រ.តត មិនទាន់បានទទួល

១៩-៣-២០១២ -អនុក្រឹត្យលេខ ៣១៦ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និង ថ្នាក់មន្ត្រីរាជការ ២១៥១

២០-៣-២០១២ -អនុក្រឹត្យលេខ ៣១៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២១៥៤
២០-៣-២០១២ -អនុក្រឹត្យលេខ ៣១៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២១៥៦
២០-៣-២០១២ -អនុក្រឹត្យលេខ ៣១៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២១៥៨
២០-៣-២០១២ -អនុក្រឹត្យលេខ ៣២០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២១៦១
២០-៣-២០១២ -អនុក្រឹត្យលេខ ៣២១ អនក្រ.តត ស្តីពី ការជូនមេដាយ ២១៦២
២០-៣-២០១២ -អនុក្រឹត្យលេខ ៣២២ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២១៦៥

III-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៣-០២-២០១២-ប្រកាសលេខ ១៨០ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ម៉ាស្ទ័រថេក ខេម អ៊ិនធើណេសិនណល បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ២១៦៧
២៣-០២-២០១២-ប្រកាសលេខ ១៨១ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អាយសោន ខេប៊ល ខេមបូ បង្កើតរោងចក្រ ផលិតឧបករណ៍ស្តាប់សម្លេងភ្ជាប់ត្រចៀក, ខ្សែតភ្ជាប់បរិក្ខារអគ្គិសនី ២១៧១
០២-៣-២០១២ -ប្រកាសលេខ ២២៩ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន យ៉ុង យីង អេច ៥ ហ្គាមេន បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ២១៧៥
០២-៣-២០១២ -ប្រកាសលេខ ២៣០ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ី ហ្គាមេន II បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ២១៧៩
០២-៣-២០១២ -ប្រកាសលេខ ២៣១ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដាយ៉ាប គ្លូបិល បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់, ស្រោមដៃ ២១៨៣

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៦១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាត្រា ម៉ាត** ២១៨៧
១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៦២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិនខេសមេន ខៀត-ខេម យ៉ាញ ស្តុត ខបភើរេសិន** ២១៨៩
១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៦៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អគ្គរ គ្លូបឹត សឺខីស** ២១៩១

១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៦៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ស្តារ ស៊ីឃ្យូរីធី (ខេមបូឌា) ខូ អិលធីឌី ២១៩៣

១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៦៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ប៊ី.ឌី.អេ.អិម. (ខេមបូឌា) ២១៩៥

១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៦៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ម៉ាធើរ សប អ៊ិនធើណេសិនណល ប្រាយវ៉េត ២១៩៧

១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៦៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អ៊ែតវ៉ានស៍ ប៊ីហ្សនេស ខនសាល់ធេនស៊ី (ខេមបូឌា) ២១៩៩

១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៧២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អាគលិត (ខេមបូឌា) ខនស្រ្តាក់សិន ឌីវេឡុបមេន ឌីហ្សាញ ខនសាល់ធេន ២២០១

១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៧៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ស្ទេម សេល អ៊ិនធើណេសិនណល (ខេមបូឌា) ២២០៣

១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៧៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ស៊ី.ធី. អេស៊ា សេប៉ ២២០៥

១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៧៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេស៊ាឡាយ ត្រាវែល ២២០៧

១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៨០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហេនឌីលី គ្រេនស្ព័រថេសិន ២២០៩

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/១៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ចំនួន ៦០រូប
ដែលមានស្នាដៃល្អ និងគុណបំណាច់ជាច្រើន ក្នុងការចូលរួមកសាងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម គី តាត　　២- ឯកឧត្តម ញៀម សារឿយ

៣- លោក ប្រាក់ ឈៀង

ខ - គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈនារីរ័ត្ន ថ្នាក់ មហាសេនា :

១- ឯកឧត្តម មិត្ត តារ៉ែន　　២- ឯកឧត្តម ហង្ស ជិចិត្រ

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១- លោកស្រី រ៉ែន សុវណ្ណនា

ឃ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១- លោក ចាន់ ស៊ីណូ　　២- ឯកឧត្តម ហាយ សីមី

៣- លោកស្រី ជាម ច័ន្ទសុជាតា　　៤- លោក ប្រាក់ ខេមរិន្ទ

៥- លោក ឈន ប៊ុនរ៉ែត　　៦- លោកស្រី ជាម ច័ន្ទរស្មី

៧- លោក ខាន់ វណ្ណន:　　៨- ឯកឧត្តម ឈាង នណារិ

៩-លោកស្រី ប្រាក់ ស៊ីណាឌី　　១០-លោកស្រី ជាម ច័ន្ទសុផារ៉ា

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ង- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១- លោក	ហៀង ថៃ	២- លោក	ធន់ សុខន
៣- លោកស្រី	អ៊ុច ចណ្ឌលីដា	៤- លោក	ហួត ប៊ុនលី

ច- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១- លោក	អួច ផាន់ណា	២- លោក	សរ គីមស្រ៊ុន
៣- លោក	ឃ្លោក សួសបុប្ផាធីន	៤- លោក	លន់ សុខា
៥- លោក	គឹម សាន	៦- លោក	ហួត ស៊ីថា
៧- លោក	ម៉ា ឌីម៉ង់	៨- លោក	នង ច័ន្ទ

ឆ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- លោក	យ៉ែម សំអួន	២- លោក	អេង តា
៣- លោក	ជា ប៉េងហួរ	៤- លោកស្រី	តែប ច័ន្ទគន្ធា
៥- លោក	ប្រាក់ ឆូល	៦- លោក	ហួន អេង
៧- លោក	ឡូច សំបូរ	៨- លោក	រត្ន័ កុសល
៩- លោក	ឡោ ផេត	១០- លោក	អេង ផល្លី
១១- លោកស្រី	កុសល យុចតី	១២-លោក	សាយ សុត្រារុណ

ជ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១- លោកស្រី	ម៉ៅ កុសាលីន	២- លោក	នេត ចាន់ស៊ីប៉ូរ៉ា
៣- លោក	លី បូណា	៤- លោក	ចាន់ រិទ្ធ
៥- លោក	ស៊ៀម ចាសនា	៦- លោក	ឃន ជី
៧- លោក	នួន ថារី	៨- លោក	គោ ចណ្ណៈ

ឈ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :

១- លោក	ហៀង សេង	២- លោក	ស្វាយ រិទ្ធី
៣- លោក	សុខ ពិសី	៤- លោក	អោក ចាន់ថន
៥- លោក	លី ត្រកាល	៦- លោក	អ៊ូ សុខា
៧- លោកស្រី	យ៉ន តូមិតា	៨- លោក	ជឹម រដ្ឋា
៩- លោក	គង់ សុម៉ាត	១០- លោកស្រី	អែម សំអាន
១១- លោក	ឡឿ សម័យ	១២- លោក	ផាយ សារិទ្ធ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចាស. ១២០៣.២០១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១២

លេខ: ២០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/១៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

នាយទាហានជាន់ខ្ពស់ ចំនួន ១២រូប មានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ ជាពិសេស ចូលរួមដឹកនាំបញ្ជាវាយបកប្រយុទ្ធការពារបូរណភាពទឹកដី ទិសប្រាសាទព្រះវិហារ និងប្រាសាទតាក្របី

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

១-	ឯកឧត្តមឧត្តមសេនីយ៍ឯក	ចាន់ រ៉ា	អត្តលេខ ០០០៣៤៧
២-	ឯកឧត្តមឧត្តមសេនីយ៍ឯក	សុខ សុវណ្ណ	អត្តលេខ ០០០៨៣៤
៣-	ឯកឧត្តមឧត្តមសេនីយ៍ឯក	អ៊ុក សុទ្ធសេន	អត្តលេខ ០០៣៩៩៩
៤-	ឯកឧត្តមឧត្តមសេនីយ៍ឯក	ឈួន ចាន់រិទ្ធ	អត្តលេខ ០០២៤៤៦
៥-	ឯកឧត្តមឧត្តមសេនីយ៍ឯក	ចិសុទ្ធ សំបូរ	អត្តលេខ ០០០៦៦៨
៦-	ឯកឧត្តមឧត្តមសេនីយ៍ឯក	លឹម សុធា	អត្តលេខ ០០០៣៣២៥
៧-	ឯកឧត្តមឧត្តមសេនីយ៍ឯក	ម៉ែត ស៊ីថា	អត្តលេខ ០០៣៣៣១
៨-	ឯកឧត្តមឧត្តមសេនីយ៍ឯក	ណឹម ម៉េង	អត្តលេខ ០៣២៥០៥
៩-	ឯកឧត្តមឧត្តមសេនីយ៍ឯក	សួស ស៊ីណា	អត្តលេខ ០០២៥៩៧
១០-	ឯកឧត្តមឧត្តមសេនីយ៍ឯក	ចាន់ សារី	អត្តលេខ ០០៣៣៣៤
១១-	ឯកឧត្តមឧត្តមសេនីយ៍ឯក	ហ៊ឹម រិន	អត្តលេខ ០០២៣៥៣
១២-	ឯកឧត្តមឧត្តមសេនីយ៍ឯក	សួន ពិរុណ	អត្តលេខ ០០៤៩៤៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣១៩. ១២០៣.២០១២

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១២

ប្រែស្រូវ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

[illegible]យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/១៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឥស្សរជនចំនួន ០៤ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយមិនទទួលប្រាក់បៀវត្ស ៖

១- ឯកឧត្តម ឧត្តមសេនីយ៍ឯក **សៀក សុជាតិ** មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន
២- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឈួន ចាន់រិទ្ធ** មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន
៣- ឯកឧត្តម ឧត្តមសេនីយ៍ទោ **នាម អឿង** មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន
៤- ឯកឧត្តម ឧត្តមសេនីយ៍ទោ **ឯក សំអួន** មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចាស. ១២០៣-២០៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១២

លេខ ១៩៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ៣ ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/១៩៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ប្រគល់ភារកិច្ចជូនលោកជំទាវ **គីម ស៊ីផាត់** ឲ្យបំពេញមុខងារជា អគ្គនាយក នៃអគ្គនាយកដ្ឋានសមភាពយេនឌ័រ និងអភិវឌ្ឍន៍សេដ្ឋកិច្ច ក្រសួងកិច្ចការនារី ។

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

ពរស.១២០៣.២០៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១២

លេខ ១.. ២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១២
អគ្គលេខាធិការ...ទីស្តីការគណៈរដ្ឋាភិបាល
ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/២០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សម្ពោធិសាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោកស្រីឧត្តមសេនីយ៍ទោ **យក់ សុខា** អត្តលេខ ០២២៥៧ នាយនគរបាលជាតិជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុក អនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រោច.១៥០៣.២០១២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១២

លេខៈ ២០៥ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មីនា ឆ្នាំ២០១២
...រាជរដ្ឋាភិបាល
... សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/២០៧

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកត/០៨០០/១៥២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០០ ស្ដីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្ដម **សង់ ស៊ីណាឡុង** ឱ្យបំពេញមុខងារជាអគ្គលេខាធិការរង នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា មានឋានៈស្មើ អគ្គនាយក។

មាត្រា ២: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣: សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខាតទៅ។

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

រាជ.១២០៣.២០៧

លេខ ៧១៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១២

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/២០៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.- ត្រូវបានតម្លើងឋានៈជូនលោកជំទាវ **សុខ ស៊ីផន** ជំនួយការសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៦៤.១២០៣.២០៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១២

លេខៈ ៤០១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ៣ ឆ្នាំ២០១២
អគ្គលេខាធិការរង [illegible] រាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/២០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្នខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន និងមន្ត្រីរាជការចំនួន ០៨រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយអភិវឌ្ឍន៍មូលដ្ឋាន លើគ្រប់វិស័យ និងជួយឧបត្ថម្ភដល់កងទ័ពនៅសមរភូមិ នៅក្នុងខេត្តពោធិ៍សាត់

នូវ

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ព្រះតេជគុណ នៅ សុគន្ធថៃ ២-ឧកញ៉ា ទ្រី ភាព

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១-លោក ឃៀង សុជីវ័ន្ត ២-លោក អួន យ៉ន់
៣-លោក ឆេ ឈឿវ

គ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១-លោក ហាន់ ស៊ីណាត ២-លោក អ៊ុក គឹមសាន
៣-លោក ជា សារិទ្ធ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារល. ១២០៣.២០៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២

លេខៈ ២០៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ មីនា ឆ្នាំ២០១២
អគ្គលេខាធិការ[illegible]រាជរដ្ឋាភិបាល
[illegible]យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/២០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

ប្រគេន

ព្រះតេជគុណឃោសបាល សៅរ៍ មុនី

ដែលបានលះបង់កម្លាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា
ក្នុងវិស័យព្រះពុទ្ធសាសនា នៅខេត្តព្រៃវែង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១៤-១២០៣-២១០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២

លេខៈ ២០២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/២០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៣១២/១៧៥ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រីរាជការ ចំនួន ៤ រូប នៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា:

១- ឯកឧត្តម **ម៉ុង ចរិយា** ជាប្រធាននៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ

២- ឯកឧត្តម **ឡាយ ម៉ារីវ៉ុ** ជាសមាជិកទី ១ នៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម **គង់ សេង** ជាសមាជិកទី ២ នៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម **សុង ឡៀង** ជាប្រធានលេខាធិការដ្ឋាន នៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា មានឋានៈស្មើ អគ្គនាយក

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

មាត្រា ២ : ប្រធាន និងសមាជិក នៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា ដូចមានចែងក្នុងមាត្រា ១ ត្រូវបានតែងតាំង សម្រាប់អាណត្តិដំបូង ។ ប្រធាន មានអាណត្តិ ៣ ឆ្នាំ សមាជិកទី ១ មានអាណត្តិ ២ ឆ្នាំ និង សមាជិកទី ២ មានអាណត្តិ ១ ឆ្នាំ ។ អាណត្តិនេះ អាចបន្តជាថ្មីទៀតបាន ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកត.១២០៣-២១១

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១២

លេខៈ ២០៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១២

អគ្គលេខាធិការរងទីស្ដីការរដ្ឋាភិបាល

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/២០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

នាយទាហានជាន់ខ្ពស់ ចំនួន ០៦រូប មានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ ជាពិសេសចូលរួមដឹកនាំបញ្ជាប្រយុទ្ធការពារបូរណភាពទឹកដី ទិសប្រាសាទព្រះវិហារ និងប្រាសាទតាក្របី

នូវ

គ្រឿងឥស្សរិយយស ជាតូបការ :

១- ឧត្តមសេនីយ៍ឯក **ម៉ៅ** **សុផាន់** អត្តលេខ ០០០៤៤៩
២- ឧត្តមសេនីយ៍ឯក **ព្រហ្ម** **ឌិន** អត្តលេខ ០០០០៣៦
៣-ឧត្តមសេនីយ៍ឯក **ហួត** **ឈាង** អត្តលេខ ០០០១៣៦
៤-ឧត្តមសេនីយ៍ឯក **យឿន** **សុវណ្ណថា** អត្តលេខ ០០០០៣៨
៥-ឧត្តមសេនីយ៍ឯក **កែវ** **សាមួន** អត្តលេខ ០០០១២៩
៦-ឧត្តមសេនីយ៍ឯក **ឌុន** **សេង** អត្តលេខ ០០០១៤៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible] ១២០៣.២០១២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២

លេខៈ២០០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ .ថ្ងៃទី១៥ ខែ មីនា ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

ស៊ឹម សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/២០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំនិងមន្ត្រីរាជការ និងនាយនគរបាលខេត្តព្រះសីហនុ ចំនួន២៥រូប
ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ កន្លងមក

នូវ

ក-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឯកឧត្តម ម៉ា ស៊ុនហួត ៣-ឯកឧត្តម អ៊ុក ដាមរី
២-ឧត្តមសេនីយត្រី តាក វណ្ណថា អត្តលេខ ០៤៤៧

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

ឯកឧត្តម ទ៉ា សុវណ្ណាថ

គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :

វរសេនីយ៍ឯក យ៉ឹម ទាសនា អត្តលេខ ០០៣៤៨៥

ឃ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍

លោក គង់ ណារិន

ង-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន ថ្នាក់ មហាសេនា :

១-ឧកញ៉ា សុខ សុខា ៣-លោក ម៉ែន សុជាតិ
២-លោក ហ៊ី ហេង

ច-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :

១-ឧកញ៉ា សូ ខួន ២-លោក សំអុល ឆារិទ្ធ

ឆ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

លោក ឆេព ទិសិដ្ឋ

ជ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

លោក គង់ សាមឿន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឈ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១-លោកជំទាវ គួច ចន្ថា ៣-លោក យស់ សុធា

២-ឯកឧត្តម ប៊ុន ហួរ ៤-លោក ឃាន សារុំ

ញ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១-លោក កេត ជិន្នរៈ

២-វរសេនីយ៍ទោហេង សារុន អត្តលេខ ០២០៦១២

៣-លោក សេង សុវណ្ណា

៤-លោក ហែម ស៊ុីវន

៥-លោក ទៀង យ៉ុង

៦-លោក នុត មករា

៧-លោកស្រី ថន ម៉ូលីដា

៨-លោកស្រី ថន ម៉ូលីណា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស.១២០៣.២១៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២

លេខ: ២១៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មីនា ឆ្នាំ២០១២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/២០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូន ឯកឧត្តម **អ៊ិច ម៉ូរ៉ា** ឲ្យបំពេញមុខងារជាប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា មានឋានៈស្មើ **អគ្គនាយក** ជំនួសឯកឧត្តម **ពឹង ស៊ីវឡាយ** ដែលត្រូវបានដាក់ឲ្យចូលនិវត្តន៍។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យ បានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.១២០៣.២១៤

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២

លេខ:២០៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ មីនា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/២១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានដំឡើងឋានន្តរសក្តិជា កិច្ចបច្ឆាមរណៈជូនសព នាយទាហានជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ

ក.ដំឡើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ឯក

- ឧត្តមសេនីយ៍ទោ **សួង កុសល** អត្តលេខ ០០០៨១៣

ខ.ដំឡើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី

- វរសេនីយ៍ឯក **អ៊ិច ឈឿន** អត្តលេខ ០០៣៩១៩

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៣.១២០៣.២១៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២

លេខ [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
អគ្គលេខ[illegible]ទី១ [illegible]រដ្ឋាភិបាល
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/២១១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឥស្សរជនចំនួន ០៣ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ដោយមិនទទួលប្រាក់បៀវត្ស ៖

១- ឯកឧត្តម **សួស យ៉ារ៉ា** មានឋានៈស្មើ **រដ្ឋមន្ត្រី**
២- ឯកឧត្តម ឧត្តមសេនីយ៍ឯក **អ៊ុយ សារិទ្ធ** មានឋានៈស្មើ **រដ្ឋមន្ត្រី**
៣- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ចាន់ នន់វិឡា** មានឋានៈស្មើ **រដ្ឋលេខាធិការ**

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ករ.១២០៣.២១២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២

លេខៈ ៧៦៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/២១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០២រូប ដែលបានខិតខំកៀរគរ និងបរិច្ចាគធនធានផ្ទាល់ខ្លួន

ចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅខេត្តសៀមរាប

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ព្រះតេជគុណ ឡាំ ឃ្លី

២- លោកជំទាវឧកញ៉ា ឈិន រីម

ថារស.១២០៣.២១៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

លេខ: ៧៦៦ ប.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០១២

[illegible]

[illegible] ជ័យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/២១៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០៤រូប ដែលបានលះបង់កម្លាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួន
ចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅខេត្តកំពង់ឆ្នាំង

នូវ

ក- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :
លោកជំទាវឧកញ៉ា ស្រី ធូទ្ធី

ខ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :
១- លោកជំទាវ គីម វ៉ាទី
២- ឧកញ៉ា អ៊ាប អេងហួង
៣- ឯកឧត្តម ស្វូ សាម៉ន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

តារទ.១២០៣-២១៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២

លេខៈ ២១០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/២១៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានប្តូរ និងតម្លើងប្រភេទក្របខ័ណ្ឌ ជូនមន្ត្រីរាជការ ចំនួន ០៩ រូប ពីមន្ត្រីក្នុងឋានន្តរស័ក្តិនាយក្រមការ ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មន្ត្រីរាជការ ក្នុងឋានន្តរស័ក្តិអនុមន្ត្រី ជាករណីពិសេស នៅក្រសួងព័ត៌មាន ៖

១	កែវ ពេជ្រនិមល	ប	ពីនាយក្រមការ ថ្នាក់លេខ ១	ទៅអនុមន្ត្រី ថ្នាក់លេខ ៥
២	ង៉ាន់ ស៊ីណា	ប	ពីនាយក្រមការ ថ្នាក់លេខ ១	ទៅអនុមន្ត្រី ថ្នាក់លេខ ៥
៣	ឡាយ ចេងលៀង	ប	ពីនាយក្រមការ ថ្នាក់លេខ ២	ទៅអនុមន្ត្រី ថ្នាក់លេខ ៧
៤	អ៊ុក ធារី	ប	ពីនាយក្រមការ ថ្នាក់លេខ ២	ទៅអនុមន្ត្រី ថ្នាក់លេខ ៧

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

៥	សំ សុខុម	ប	ពីនាយក្រមការ ថ្នាក់លេខ ៣	ទៅអនុមន្ត្រី ថ្នាក់លេខ ៨
៦	ឌិ សារឿន	ប	ពីនាយក្រមការ ថ្នាក់លេខ ៥	ទៅអនុមន្ត្រី ថ្នាក់លេខ ១២
៧	ជា ក្រូច	ប	ពីនាយក្រមការ ថ្នាក់លេខ ៥	ទៅអនុមន្ត្រី ថ្នាក់លេខ ១២
៨	គ្រី ចំរើន	ប	ពីនាយក្រមការ ថ្នាក់លេខ ៦	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៩	ចៅ សាង	ប	ពីនាយក្រមការ ថ្នាក់លេខ ៦	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៥៩. ១២០៣. ២១៩

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២

លេខៈ ២៦៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ [illegible] ខែ មីនា ឆ្នាំ២០១២

អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៤.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៧.៦៦៨ ហិកតា ក្នុងតំបន់ឧទ្យានជាតិសុរាម្រិត-កុសមៈ "គិរីរម្យ" ស្ថិតនៅក្នុងភូមិសាស្រ្ត ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ២០០៨ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បកចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១:

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៧.៦៦៨ (ប្រាំពីរពាន់ប្រាំមួយរយហុកសិបប្រាំបី) ហិកតា ក្នុងតំបន់ឧទ្យានជាតិសុវាម្រិត-កុសមៈ "គីរីរម្យ" ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ក្រោមលក្ខខ័ណ្ឌសម្បទាន ដើម្បីធ្វើអាជីវកម្មចៀរជ័រស្រល់ កាប់ឆ្ការ ផ្លាស់ប្តូរដាំដើមស្រល់បន្ថែម និងបង្កើតរោងចក្រ កែច្នៃផលិតផលជ័រស្រល់ ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ១៥៨២ សជណ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២:

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

មាត្រា៣:

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៤:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ២.០០០ ហិកតាក្នុងតំបន់ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ "គីរីរម្យ" ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ខែ ឧសភា ឆ្នាំ ២០០៨ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១:

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ២.០០០ (ពីរពាន់) ហិកតា ក្នុងតំបន់ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ "គីរីរម្យ" ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ ក្រោមល័ក្ខខ័ណ្ឌសម្បទានដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ១៥៨៣ សជណ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២:

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

មាត្រា៣:

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០១២

រាជរដ្ឋាភិបាល ទីស្តីការគណៈរដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>*កន្លែងទទួល:*</u>

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ៤
- -រាជកិច្ច
- -ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៦ អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.៨៩២ ហិកតាក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំព្រេច ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តមណ្ឌលគីរី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ខែ ឧសភា ឆ្នាំ ២០០៨ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១២ ស្ដីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១:

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ៦.៨៩២(ប្រាំមួយពាន់ប្រាំបីរយកៅសិបពីរ) ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំព្រេច ស្ថិតក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី ក្រោមល័ក្ខខ័ណ្ឌសម្បទានដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម ដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកាដែលជាឯកសារភ្ជាប់ នឹងលិខិតលេខ ០១សជណ ចុះថ្ងៃទី ០៣ ខែមករា ឆ្នាំ២០១២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២:

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

មាត្រា៣:

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៧-អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៣.១១០ ហិកតាក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំព្រេច ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ខែ ឧសភា ឆ្នាំ ២០០៨ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១:

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៣.១១០ (បីពាន់មួយរយដប់) ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំព្រេច ស្ថិតក្នុងភូមិសាស្ត្រខេត្តមណ្ឌលគីរី ក្រោមល័ក្ខខ័ណ្ឌសម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់ នឹងលិខិតលេខ ១២២សជណ.កសចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា២:

